# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Oct-2015, 14:15
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង សំណើលើកទីប្រាំមួយ ពាក់ព័ន្ធនឹងភស្តុតាងបន្ថែមលើបណ្ដឹងសាទុក្ខប្រឆាំង នឹងសាលក្រមសំណុំរឿង ០០២/១

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

Victor KOPPE

ព្រំ ផល្លា

លីវ សុវណ្ណា

Doreen CHEN

Xiaoyang NIE
Marina HAKKOU
Henri DECŒUR

ផ្ញើជូន៖

**សហមេធាវី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**PICH Ang**
Marie GUIRAUD

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ សហមេធាវីការពារក្តីរបស់ នួន ជា ("មេធាវីការពារក្តី") បានដាក់សំណើលើកទីប្រាំមួយសុំឱ្យពិចារណា និង ទទួលយកភស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ("សំណើសុំភស្តុតាងបន្ថែមលើកទីប្រាំមួយ") តែមួយភាសាជាភាសាអង់គ្លេស[1] និងភាសាខ្មែរនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥។ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា ឬ ចម្លើយតប")[2]។ នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានស្នើដាក់សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា តែមួយភាសាជាភាសាអង់គ្លេស[3] តែអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធនៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥[4]។ ដោយអនុលោមតាមមាត្រា ៨.៤ នៃការណែនាំអំពីការដាក់ឯកសារនៅចំពោះមុខ អវតក មេធាវីការពារក្តីសូមដាក់ការឆ្លើយតបនេះទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ("ការឆ្លើយតប")។

២. ដោយសារតែជាបញ្ហាបឋម មេធាវីការពារក្តីសូមលើកឡើងថា ការឆ្លើយតបនេះគួរតែធ្វើចំណាត់ថ្នាក់ជាសាធារណៈ។ ព័ត៌មានដែលបង្ហាញគឺបានមកជាសាធារណៈ ឬក៏ពីសារណាសម្ងាត់របស់មេធាវីការពារក្តី ដែលមានលក្ខណៈមិនគួរជាសម្ងាត់ ហើយក៏គ្មានមូលហេតុ

---

[1] **F2/8** "សំណើលើកទី៦ របស់ នួន ជា ស្នើសុំឱ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើសុំភស្តុតាងបន្ថែមលើកទីប្រាំមួយ")។

[2] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦ របស់ នួន ជា សុំឱ្យមានការពិចារណា និងទទួលភស្តុតាងបន្ថែម ទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា)។

[3] សារអេឡិចត្រូនិចពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់មេធាវីការពារក្តីជូនអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥។

[4] សារអេឡិចត្រូនិចពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះតុលាការកំពូល ជូនទីប្រឹក្សាច្បាប់របស់មេធាវីការពារក្តី ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥។

ដែលមេធាវីការពារក្តីស្នើសុំធ្វើចំណាត់ថ្នាក់ដូច្នោះទេ[5]។ ដោយពិចារណាដល់លក្ខណៈសំខាន់នៃអំណះអំណាងរបស់មេធាវីការពារក្តី វានឹងជាប្រយោជន៍សម្រាប់សាធារណៈជនក្នុងការចាត់ចំណាត់ថ្នាក់ការឆ្លើយតបនេះជាឯកសារសាធារណៈ។

## II. អំណះអំណាង

៣. ចម្លើយតបរបស់សហព្រះរាជអាជ្ញាគឺជាការអស់សង្ឃឹមដ៏អស្ចារ្យមួយ។ មេធាវីការពារក្តីបានរំពឹងថា វានឹងជាឱកាសមួយសម្រាប់ការពិភាក្សាដ៏មានអត្ថន័យអំពីអំណះអំណាងសំខាន់ៗនៅក្នុងសំណើរួមទីប្រាំមួយរបស់ខ្លួន។ តែផ្ទុយទៅវិញសហព្រះរាជអាជ្ញាខកខានក្នុងការធ្វើដូច្នេះ។ ខ្លួនគ្រាន់តែផ្តោតសំខាន់តែម្យ៉ាងគឺអំពីយុទ្ធនាការរបស់ខ្លួនប្រឆាំងនឹងមេធាវីការពារក្តី (ដែលហាក់ដូចជាបានចាប់ផ្តើមនៅមិនយូរ បន្ទាប់ពីការមកដល់របស់សហព្រះរាជអាជ្ញាបរទេស Nicholas Koumjian[6] ដោយដើរតួវាយប្រហារបង្កាច់ទៅលើចេតនា ការប្រព្រឹត្ត និង ការការពារក្តីជាទូទៅរបស់មេធាវីការពារក្តី។

៤. អាស្រ័យហេតុនេះហើយមេធាវីការពារក្តីសូមយោងទៅលើអំណះអំណាងជាសារធាតុដែលខ្លួនបានលើកឡើងនៅក្នុងសំណើលើកទី៦របស់ខ្លួន។ មេធាវីការពារក្តីសូមកម្រិតនៅក្នុងការ

---

[5] ទាក់ទងនឹងបញ្ហានេះ មេធាវីការពារក្តីកត់សម្គាល់ថា កថាខណ្ឌ ១៣ ១៤ ខាងក្រោម គឺយកចេញពីសារណាសម្ងាត់របស់ខ្លួន **F2/4/3/3/4** "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ជូនអង្គជំនុំជម្រះតុលាការកំពូលឲ្យស៊ើបអង្កេតបន្ថែមទៅនឹងខ្សែវីដេអូរបស់ផលិតករ ROB LEMKIN និង ថេត សម្បត្តិ " ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ ("សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអំពីកំណត់ហេតុរបស់ Lemkin ) កថខណ្ឌ ៣ និង **F28/3** "សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាទៅនឹងសំណើសុំឲ្យស៊ើបអង្កេតអំពីព្រឹត្តិការណ៍ដែលពិពណ៌នាក្នុងអំឡុងពេលសក្ខីកម្មរបស់ សំ សិទ្ធី" ៧ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ២៧។ តែកថាខណ្ឌ ១០ ផ្តល់ការពិភាក្សាមានកម្រិតនៃ **F2/4/3/3/6/1** "សារណារបស់ នួន ជា អំពីប្រតិចារិតរបស់ Lemkin និងសារសំខាន់នៃ "ជម្លោះ" នៅក្នុង បកក" ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៥ (សារណាអំពីប្រតិចារិតLemkin និងជម្លោះក្នុង បកក")។

[6] *សូមមើលដូចជា* **F2/6/2** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៤របស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទី៤") កថាខណ្ឌ ៥។ **F2/7/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៥" ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ៣។ សូមមើលផងដែរ **F2/8** "សំណើលើក៦" កថាខណ្ឌ ១៦។

ឆ្លើយតបនេះតែចំពោះបញ្ហាពីរគឺ៖ អ្វីដែលខ្លួនជឿជាក់ថា សហព្រះរាជអាជ្ញាបានបកស្រាយខុសអំពីជំហររបស់មេធាវីការពារក្តី និងអំពីការដែលសហព្រះរាជអាជ្ញាបកស្រាយច្បាប់ជាធរមានមិនត្រឹមត្រូវ។ អំណះអំណាងទាំងអស់នៅក្នុងការឆ្លើយតបនេះបញ្ជាក់ឡើងវិញអំពីអំណះអំណាងរបស់មេធាវីការពារក្តី ដែលបានលើកឡើងរួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ តែទោះបីជាយ៉ាងណាក៏ដោយវានឹងច្រំដែល តែដើម្បីភាពងាយស្រួលមិនមែនសម្រាប់តែអង្គជំនុំជម្រះសាលាដំបូងទេ តែដោយសារតែសហព្រះរាជអាជ្ញា មិនបានអាន ឬក៏យល់មិនបានច្បាស់អំពីអំណះអំណាងរបស់មេធាវីការពារក្តីនោះទេ។

**ក. សហព្រះរាជអាជ្ញាបកស្រាយខុសអំពី ចេតនា ការប្រព្រឹត្ត និង ការការពារក្តីជាទូទៅ**

៥. មេធាវីការពារក្តីបានចំណាយ២៥ទំព័រនៅក្នុងសំណើលើកទី៦របស់ខ្លួនដើម្បីបង្ហាញដោយប្រយ័ត្នប្រយែងអំពីអំណះអំណាងដើម្បីគាំទ្រដល់រឿងរ៉ាវរបស់ នួន ជា អំពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុងដែនយុត្តាធិការរបស់ អវតក ដែលគាំទ្រដោយ២៥ទំព័រទៀតក្នុងការវិភាគអំពីភស្តុតាងដែលពាក់ព័ន្ធដែលបានស្នើឲ្យទទួលយកជាភស្តុតាង។ បន្ថែមពីលើនេះទៀតមេធាវីការពារក្តីបានព្យាយាមបង្ហាញការការពារក្តីរបស់ខ្លួននៅពេញសវនាការសំណុំរឿង ០០២/០១ និង បណ្តឹងសាទុក្ខ។ នៅក្នុងអំឡុងពេលបណ្តឹងសាទុក្ខក្នុងពេលបច្ចុប្បន្ននេះ មេធាវីការពារក្តីបានលើកឡើងអំពីអំណះអំណាងទាំងនេះយ៉ាងលម្អិតនៅក្នុងសារណាបណ្តឹងសាទុក្ខ[7] (“បណ្តឹងសាទុក្ខ”) និង សារណាផ្សេងៗទៀត[8] ដោយរាប់ទាំងសំណើលើកទី៧ក្នុងពេលខាងមុខស្នើសុំឲ្យទទួលយកភស្តុតាងបន្ថែម[9]។

---

[7] **F16**, “បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១” ថ្ងៃទី ២៩ ធ្នូ ឆ្នាំ ២០១៤។

[8] *សូមមើលផងដែរ* **F2/4/3/3/6/1** “សារណារបស់ នួន ជា អំពីប្រតិចារិតរបស់ Robert Lemkin និង សារសំខាន់នៃជម្លោះនៅក្នុង បកក”។ **F2/4/3/3/1** “ចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅក្នុងឈុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត ROB LEMKIN និង ថេត សម្បត្តិ” ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥។ **F2/4/3/3/4** “ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា”។

[9] (១) ឯកសារ **F2** “សំណើសុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១” ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ (ទាក់ទិននឹងភស្តុតាងដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត ថេត សម្បត្តិ និង Rob Lemkin)។ (២) ឯកសារ **F2/1** “សំណើលើកទីពីរស្នើសុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គ ជំនុំជម្រះសាលា

៦. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានចោទប្រកាន់មេធាវីការពារក្តីចំនួន *១៩ដង* អំពីការបំភាន់អង្គជំនុំជម្រះតុលាការកំពូលអំពីលក្ខណៈ និងសារសំខាន់នៃភស្តុតាងដែលបានស្នើនៅក្នុងសំណើលើកទី៦[10]។ សហព្រះរាជអាជ្ញាបានស្នើឡើងចំនួន *៧ដង*ទៀតថា គ្រប់ផ្នែកទាំងអស់សម្រាប់គម្រោងការមួយរបស់មេធាវីការពារក្តីក្នុងការរំខាន និងពន្យារពេល[11]។ តាមរយៈការធ្វើដូច្នេះ ឧទាហរណ៍ដូចជា សហព្រះរាជអាជ្ញាខកខានក្នុងការបង្ហាញភស្តុតាងសម្រាប់ការពិចារណាទៅលើបញ្ហាអំពីការទទួលស្គាល់របស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងការលើកឡើងវិញអំពីគម្រោងបញ្ចប់របស់ អវតក ដែលថាការដាក់សំណើបន្ថែម នាំទៅដល់ *"ការអនុវត្តសិទ្ធិអំពីនីតិវិធី"* សម្រាប់ នួន ជា[12] និងអាស្រ័យហេតុនេះហើយពិតជាស្របច្បាប់សម្រាប់សំណើ។

---

ដំបូងនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ (ទាក់ទិននឹងវីដេអូនៃកិច្ចសម្ភាសន៍ជាមួយលោកស្រី Silvia Cartwright និងសម្រង់អត្ថបទពីសៀវភៅរបស់លោក Marcel Lemonde)។ (៣) ឯកសារ **F2/4** "សំណើ លើកទីបីស្នើសុំឲ្យទទួល និងពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("សំណើសុំភ័ស្តុតាងបន្ថែមលើកទីបី") (ទាក់ទិននឹងភ័ស្តុតាងពីសាក្សីលើបណ្តឹងសាទុក្ខ ទាត់ ធឿន)។ (៤) ឯកសារ **F2/6** "សំណើលើកទីបួនរបស់ នួន ជា ស្នើសុំឲ្យពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/ ០១" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ ("សំណើសុំភ័ស្តុតាងបន្ថែមលើកទីបួន") (ទាក់ទិននឹងភ័ស្តុតាងសាក្សីជំនុំជម្រះលើសំណុំរឿង ០០២/០១ និង ០០២/០២ ពេជ ជីម)។ និង (៥) ឯកសារ **F2/7** សំណើសុំដាក់ភ័ស្តុតាងបន្ថែមលើកទីប្រាំ (ទាក់ទិននឹងភ័ស្តុតាងនៃការបះបោរ និង/ឬ អំពើក្បត់នៅភូមិភាគពាយ័ព្យ)។ (៦) ឯកសារ **F2/8** សំណើលើកទី៦ និង (៧) **F2/4/3/3/6/1** "សារណារបស់ នួន ជា អំពីប្រតិចារិតរបស់ Robert Lemkin និង សារសំខាន់នៃជម្លោះនៅក្នុង បកក"។

[10] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" ដោយបានចោទប្រកាន់មេធាវីការពារក្តី "បំភាន់" អង្គជំនុំជម្រះ (ថាខណ្ឌ ៣, ៥០, ៥៦, ៥៩, ៨២, ៨៣, ៩០, ៩២) ភស្តុតាង។

[11] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" ដោយបានចោទប្រកាន់មេធាវីការពារក្តី ថាព្យាយាមបន្ត "រំខាន និង យុទ្ធសាស្ត្របណ្តឹងអប្រសិទ្ធភាព" (កថាខណ្ឌ ៩៧) "ពន្យារពេល"ដំណើការនីតិវិធី (កថាខណ្ឌ ៤ និង ៧) អូសបន្លាយពេលវេលា និង អូសបន្លាយមិនសមហេតុផល (កថាខណ្ឌ ៦១ និង ១៣) និង បានខិតខំទប់ស្កាត់មិនឲ្យចេញសាលក្រមស្ថាពរក្នុងសំណុំរឿង ០០២/០១ តាមដែលអាចធ្វើទៅបាន (កថាខណ្ឌ ៩១)។

[12] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *ផែនការពេញលេញ (វសេធន ៦)* ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៤០ អាចរកបាននៅគេហទំព័រ http://www.eccc.gov.kh/sites/default/files/ ECCC_Completion_Plan_Rev_6.pdf

៧. សហព្រះរាជអាជ្ញាបន្ទាប់មកលើកឡើងជាច្រើននៅក្នុងចម្លើយតបរបស់ខ្លួនដោយគ្រាន់តែស្តីបន្ទោសដល់ការការពារក្តីរបស់មេធាវីការពារក្តី ដែលខ្លួនបានលើកឡើងជិត *៦០ដង*[13] ដោយប្រើប្រាស់លទ្ធភាពច្រើនបំផុតអំពីការអស់សង្ឃឹម នៅក្នុងការជឿជាក់ថា វេចនាស័ព្ទវានឹងល្អជាងនិយាយអំពីហេតុផល និង ភស្តុតាង និងនៅក្នុងការការខិតខំច្បាស់លាស់ដើម្បីបន្ទាបតម្លៃរបស់មេធាវីការពារក្តីជាមួយនឹងការលើកឡើងអំពីការរួមគំនិត "បដិសេធ Holocaust"[14] ដោយរារាំងមិនឱ្យភស្តុតាងត្រូវបានពិចារណា។ ការកត់សម្គាល់បំផុតនោះ គឺការលើកឡើងរបស់សហព្រះរាជអាជ្ញាអំពីយុទ្ធសាស្ត្ររបស់មេធាវីការពារក្តីថាជាការ "អះអាងបែបខ្វះការ

---

[13] *សូមមើល* **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" ដោយបានពិពណ៌នាអំពីអំណះអំណាងរបស់មេធាវីការពារក្តីថាជា "ការឃុបឃិត" (កថាខណ្ឌ ៥ និង ២១ និង ជើងទំព័រ ២៨) "បំភាន់ការពិត" (កថាខណ្ឌ ៣៣) កាប៉ុនប៉ងដើម្បី "បំផុសន័យ" (កថាខណ្ឌ ៦៨) "លើកឡើងមិនត្រឹមត្រូវ" (កថាខណ្ឌ ៥៧) "ស្មាន" (កថាខណ្ឌ ៣ ២៣ ៤៤ ៤៥ ៧១ ៩៩ និង ១០៦) និង "មិនពាក់ព័ន្ធ" (កថាខណ្ឌ ២៩ ៤៩ ៥៥ និង ១០៦) "មិនគាំទ្រ" (កថាខណ្ឌ ១៨ និង ២០) "មិនច្បាស់" (កថាខណ្ឌ ១០៧) "មិនពាក់ព័ន្ធ" (កថាខណ្ឌ ២, ២៨ និង ៦១) "គួរឱ្យសង្ស័យ" (កថាខណ្ឌ ១៨ និង ៩៥) "មិនគួរឱ្យកត់សម្គាល់" (កថាខណ្ឌ ៦៨) "ឥតបានការ" (កថាខណ្ឌ ៤ និង ១០៧) "មិនពាក់ព័ន្ធ" (កថាខណ្ឌ ១០៧) "ស្ថិតនៅក្រៅរង្វង់" (កថាខណ្ឌ២) "មិនត្រឹមត្រូវ" (កថាខណ្ឌ ៥០ ៥៨ ៩៨) "សម្តីឥតខ្លឹមសារ" (កថាខណ្ឌ ៦) "មានភាពពាក់ព័ន្ធតិចតួច"ទៅនឹងសំណើ (កថាខណ្ឌ ១៨) "ជ្រើសរើស" (កថាខណ្ឌ ១៨) "គ្មានសំអាងហេតុពិតអ្វីទាល់តែសោះ" (កថាខណ្ឌ ២២) "ការយល់ឃើញតាមចំណង់ចិត្តរបស់ខ្លួន" (កថាខណ្ឌ ២២) "ការនិទានរឿង" (កថាខណ្ឌ ២៣) ការប៉ុនប៉ះប៉ូវនូវភាពបរាជ័យ (កថាខណ្ឌ ២៥) ផ្អែកលើ "ការធ្វើឱ្យចុះខ្សោយភាពរឹងមាំ"(កថាខណ្ឌ ២៨) "ធ្វើឱ្យខូច" (កថាខណ្ឌ ២៩) "ប៉ុនប៉ងរៀបរាប់" (កថាខណ្ឌ ៣៥) ការប៉ុនប៉ង "បន្ថែម និង គាំទ្រឡើករណ៍បណ្តឹងសាទុក្ខ" (កថាខណ្ឌ ៣៥) ខកខាន "ក្នុងការបង្ហាញទំទាន់ទំនងជាក់លាក់" (កថាខណ្ឌ ៣៦) "ដោយឥតអៀនខ្មាស់" (កថាខណ្ឌ ៥០) "មិនគ្រប់គ្រាន់" (កថាខណ្ឌ ៥២) "ពិតជាមិនច្បាស់លាស់" (កថាខណ្ឌ ៦០) "សុំឱ្យទទួលយកភាស្តុតាងដែលគាំទ្រជំហររបស់ខ្លួន" (កថាខណ្ឌ ៦២) "មិនអាចជឿជាក់បាន" (កថាខណ្ឌ ១០៥) "គ្មានមូលដ្ឋាន" (កថាខណ្ឌ ១០៨) និង ជើងទំព័រ ១២ ដល់ ១៨ *ខាងក្រោម*។

[14] សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian បានបញ្ចូលរួចមកហើយថា ការបន្តយុទ្ធសាស្ត្រដូច្នេះ៖ នៅការពិភាក្សាថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០១៥ នៅ អវតក ដែលរៀបចំឡើងដោយ Raoul Wallenberg Institute សម្រាប់និស្សិតកម្ពុជា និងបុគ្គលិក អវតក។ នៅពេលនោះដែលមានវត្តមាន សហមេធាវីអន្តរជាតិរបស់ នួន ជា Victor Koppe ជាអ្នកធ្វើបទបង្ហាញមួយដែរនោះលោក Koumjian បាននិយាយថា នៅពេលដែល Holocaust ត្រូវបានបដិសេធនៅប្រទេសបារាំង មេធាវីការពារក្តីនៅទីនេះមានសេរីភាពក្នុងការពិភាក្សាអំពីទ្រឹស្តីអ្វីក៏ដោយឱ្យតែខ្លួនពេញចិត្ត។

ទុកចិត្ត[15] "ការនិយាយច្រំដែលមិនឈប់ឈរ"[16] "អត្ថបដិរូប"[17] "ឧបមា"[18] "យុត្តិសាស្ត្រមិនល្អមួយដែលប៉ះពាល់ដល់ទិដ្ឋភាពនៃភាពប្រាកដនិយម"[19] និង "បែបរវើរវាយ"[20] និង "ប្រវត្តិសាស្ត្រខ្មែរក្រហមបែបសេរីនិយម"[21]។ នេះជាបច្ចេកទេសដែលសហព្រះរាជអាជ្ញាប្រើប្រាស់នៅពេលកន្លងមក ជាពិសេសអំពីការប៉ុនប៉ងដើម្បីដកចេញភស្តុតាងមានការពាក់ព័ន្ធបំផុតដែលប្រមូលដោយផលិតករខ្សែភាពយន្ត Robert Lemkin[22]។

---

[15] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ១៩។

[16] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៣២។

[17] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៣។

[18] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៣ និង ២១។

[19] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៣៨។

[20] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៣២។

[21] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ២៤។

[22] សហព្រះរាជអាជ្ញាមិនបានលើកឡើងថា ខ្លួនបានស្នើសុំប្រើប្រាស់យ៉ាងច្រើនអំពីខ្សែភាពយន្តដែល Robert Lemkin និង ថេត សម្បត្តិ បានផលិត ហើយបានយោងជាដដែលនៅក្នុងសវនការ (*សូមមើល* **F2/4/3/3/4** "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ជូនអង្គជំនុំជម្រះតុលាការកំពូល ឲ្យស៊ើបអង្កេតបន្ថែមទៅនឹងខ្សែវីដេអូរបស់ផលិតករ Robert Lemkin និង ថេត សម្បត្តិ" កថាខណ្ឌ ១៣ ដល់ ១៥) ដាក់ជូនអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងខែ កញ្ញា ឆ្នាំ ២០១៤ថា "ជំនាញស៊ើបអង្កេតរបស់ ថេត សម្បត្តិ មិនអាចជាបញ្ហានោះទេ" (**F2/2** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទី១ និងទី២របស់នួន ជា" ថ្ងៃទី១៦ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ១០) និង ការប៉ុនប៉ងការពារប្រឆាំងទៅនឹងភាពផ្ទុយគ្នាយ៉ាងច្បាស់ក្រឡែតនេះ ដោយបានព្យាយាមមិនទំនងក្នុងការញែក Robert Lemkin ចេញពី ថេត សម្បត្តិ (សូមមើល **F2/4/3/3/4** "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា" កថាខណ្ឌ ១៤។ ទោះជាយ៉ាងណាក៏ដោយនៅពេលដែលមេធាវីការពារក្ដីប៉ុនប៉ងប្រើប្រាស់លើភស្តុតាងរបស់ Lemkin សហព្រះរាជអាជ្ញាបែរជាជំទាស់ហើយព្យាយាមបង្ខូចភស្តុតាងរបស់ Robert Lemkin៖

(១) ភាពមិនលំអៀងរបស់ Robert Lemkin: សហព្រះរាជអាជ្ញាបានពិពណ៌នាភស្តុតាងដែលបានប្រមូលថាជាផ្នែកនៃ "ការប្រឹងប្រែងមាំមួន តែមិនបានជោគជ័យដោយអ្នកនិពន្ធជីវប្រវត្តិតាមការជ្រើសរើសរបស់ នួន ជា ដើម្បីធ្វើឲ្យមានសុពលភាពយ៉ាងហោចណាស់លើការអះអាងរបស់គាត់ថា បានដឹកនាំចលនានយោបាយមួយដោយមានបញ្ចូលចារកម្ម និងភ្នាក់ងារនៃរដ្ឋាភិបាលបរទេស" (**F2/4/3/3/6/3**, ការសន្និដ្ឋានសហព្រះរាជអាជ្ញាលើប្រតិចារិតនៃការសម្ភាសន៍ដែលទទួលបានរបស់ Robert Lemkin" ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ ("សេចក្ដី

សន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើប្រតិចារិតរបស់ Robert Lemkin") និងបានលើកឡើងថាដំណើរការនៃការសម្រេចរបស់ Lemkin អំពីអ្នកដែលត្រូវសម្ភាសន៍ តើសំណួរអ្វីត្រូវសួរសាក្សី និងសម្ភារៈអ្វីត្រូវជ្រើសរើសសម្រាប់ភាពយន្ត និង សៀវភៅរបស់ពួកគេ អាចនឹងមានឥទ្ធិពលដោយ "ចំណងទាក់ទងជិតស្និទ" ដែលបង្កើតឡើងរវាងអ្នកសហការរបស់គាត់ ថេត សម្បត្តិ និង នួន ជា (**F2/4/3/3/3**, "សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាទាក់ទងនឹងការស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលទៅក្នុង Footage ដែលជាកម្មសិទ្ធិរបស់ Robert Lemkin និង ថេត សម្បត្តិ" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ("សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកំណត់ត្រា របស់ Robert Lemkin") នៅកថាខណ្ឌ១៨)។

(២) ជំនាញរបស់ Robert Lemkin: សហព្រះរាជអាជ្ញាបានពិពណ៌នា Robert Lemkin ថាជាអ្នកដែល "មិនអាចចាត់ទុកជាអ្នកជំនាញ" ដែលមានចំណេះដឹងកម្រិតនៃ ប.ក.ក និង របបកម្ពុជាប្រជាធិបតេយ្យ និងគ្មានជំនាញ" (**F2/4/3/3/3**, សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកំណត់ត្រា របស់ Robert Lemkin") នៅកថាខណ្ឌ ១៥, ៣៩, ២១ និង ២៣)។

(៣) ចំណង់របស់ Robert Lemkin: សហព្រះរាជអាជ្ញាបានប៉ុនប៉ងបង្កើតឲ្យមានមន្ទិលសង្ស័យលើចំណង់របស់ Robert Lemkin នៅក្នុងការសម្ភាសន៍សាក្សី ដោយបានកត់សម្គាល់ថា Lemkin បានយកចេញអត្តសញ្ញាណរបស់ សាក្សី តួនាទីរបស់ពួកគេនៅពេលវេលាពាក់ព័ន្ធ ព្រមទាំងអាយុ និង កម្រិតសិក្សារបស់ពួកគេ" សំរាប់មូលហេតុនានាដែលនៅតែមិនច្បាស់នៅឡើយ ដោយបានកត់សម្គាល់ថា "កាលៈទេសៈនៃការសម្ភាសន៍របស់ Lemkin នៅតែមិនច្បាស់ឡើយ។ ជាពិសេស មិនមានអ្វីចង្អុលបង្ហាញថាតើមានការសន្យាអ្វីខ្លះដល់អ្នកដែលត្រូវសម្ភាសន៍" "នរណាបកប្រែសំដីរបស់អ្នកសម្ភាសន៍ [Lemkin] ទៅជាភាសាអង់គ្លេស [និង] ថាតើបុគ្គលនោះ មានប្រយោជន៍នៅក្នុងបញ្ហានេះដែរ ឬយ៉ាងណា" និងបាននិយាយមិនចំថា Lemkin បានដកទុកភស្តុតាងផ្សេងៗដោយមិនមានមូលហេតុពីអង្គជំនុំជម្រះនេះ (**F2/4/3/3/6/3** សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងប្រតិចារិតរបស់ Robert Lemkin") នៅកថាខណ្ឌ១៣ និង

(៤) វិធីសាស្ត្ររបស់ Robert Lemkin: សហព្រះរាជអាជ្ញាបានរិះគន់ជាច្រើនលើវិធីសាស្ត្ររបស់ Lemkin ដោយបានយោងទៅលើការកត់សម្គាល់ "ភាពមិនអាចជឿជាក់បាននៃការវិភាគរបស់គាត់" និង "វិធីសាស្ត្រមិនច្បាស់លាស់" សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកំណត់ត្រារបស់ Robert Lemkin") នៅកថាខណ្ឌ ២២ និង ៩) ។ សូមមើលផងដែរ **F2/4/3/3/6/3**, សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងប្រតិចារិតរបស់ Robert Lemkin") នៅកថាខណ្ឌ១៣។

៨. ក្រៅតែដើរស្តីបន្ទោសនៅតាមផ្លូវទីផ្លាសាលា និងបើទោះជាមានការខិតខំរបស់មេធាវីការពារក្តីក្នុងការបង្ហាញនូវការពិភាក្សារួមមួយអំពីការការពារក្តីរបស់ខ្លួន និងភស្តុតាងគាំទ្រការឆ្លើយតបជាសារធាតុរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងតែអំពីការរអ៊ូរទាំមិនច្បាស់លាស់ទៅលើភស្តុតាងនិមួយៗដែលមេធាវីការពារក្តីបានស្នើឡើង[23]។ មេធាវីការពារក្តីសូមមិនឆ្លើយតបទៅនឹងការរអ៊ូរទាំនេះទេ ព្រោះថា សំណើទី៦បានលើកឡើងអំពីសារសំខាន់នៃភស្តុតាងនីមួយៗយ៉ាងច្បាស់រួចហើយ។ ជាងទៅនេះទៀត មេធាវីការពារក្តីស្នើឡើងថា តាមរយៈការពិចារណាលើភស្តុតាងដែលបានស្នើនូវបំណែកតូច និងការខកខានក្នុងការបញ្ជាក់អំពីសារៈសំខាន់នៃការការពារក្តីរបស់មេធាវីការពារក្តីទាំងមូល ព្រះរាជអាជ្ញាខកខានក្នុងជំទាស់ទៅនឹងអំណះអំណាងសំខាន់នៃសំណើលើកទី៦៖ ដែលថា ភស្តុតាងដែលបានស្នើទាំងអស់ពិតជាបង្ហាញអំណះអំណាងរបស់ នួន ជា ដែលថា ការបែកបាក់នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា (“បកក”) ដែលដឹកនាំដោយ សោ ភឹម និង រស់ ញឹម ត្រូវបានគាំទ្រដោយវៀតណាមក្នុងការបង្កការបះបោរ និងព្យាយាមធ្វើរដ្ឋប្រហារប្រឆាំងនឹងប៉ុល ពត នួន ជា និងរដ្ឋាភិបាលស្របច្បាប់កម្ពុជាប្រជាធិបតេយ្យ (“ផែនការ ក”) បើខកខានវៀតណាមដែលគាំទ្រដោយសហភាពសូវៀត នឹង(ហើយបានធ្វើ)ឈ្លានពានដោយផ្ទាល់ (“ផែនការ ខ”)[24]។

៩. ការលើកឡើងជិតត្រូវរបស់សហព្រះរាជអាជ្ញា ទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តីគឺនៅពេលដែលពួកគេលើកឡើងអំពីការពិពណ៌នា Manichean ដោយស្នើឡើងថា បើទោះជាការបះបោរផ្ទៃក្នុងពិតជាបានកើតមានមែន វាមិនមានការភ្ញាក់ផ្អើលនោះទេ ដោយសារតែបកក បង្កតែ “ទុក្ខភាព និង ការភ័យខ្លាច”។ អាស្រ័យហេតុនេះហើយវាហាក់ដូចជាថាសហព្រះរាជអាជ្ញា នឹងគិតថាមេដឹកនាំបះបោរគឺជាអ្នកតស៊ូដើម្បីសេរីភាពដែលសកម្មភាពក្បត់របស់ខ្លួនត្រូវបានកែតម្រូវដោយសារតែមូលហេតុរបស់វា ដែលមេដឹកនាំបះបោរដោយរាប់ទាំងបុគ្គលឃោរឃៅ និងឱកាសនិយម ដែលជាមេដឹកនាំភូមិភាគពាយ័ព្យ រស់ ញឹម ដែលមេធាវីការពារក្តីអះអាងថា បានទទួលខុសត្រូវលើឧក្រិដ្ឋកម្មឃោរឃៅនៅទួលពោធិជ្រៃដែល

---

[23] **F2/8/5** “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦” កថាខណ្ឌ ៤៣ ដល់ ១០៨។

[24] **F2/8** “សំណើលើកទី៦” កថាខណ្ឌ ១០ ដល់ ១២ និង ២៣ ដល់ ៦៩។

ជាចំណុចនៃសំណុំរឿង ០០២/០១[25]។ តាមពិតទៅ ឧទាហរណ៍ជាបដិរូបបំផុតរបស់សហព្រះរាជអាជ្ញាគឺការខកខានរបស់សហព្រះរាជអាជ្ញាក្នុងការចូលរួមដ៏មានអត្ថន័យទៅលើអំណះអំណាងដែលបានលើកឡើងនៅក្នុងសំណើលើកទី៦គឺថា បើទោះជា ការស្នើឡើងដោយមេធាវីការពារក្តី ដែលថា វៀតណាមបានដើរតួនាទីសំខាន់ក្នុងព្រឹត្តិការណ៍ដែលបានដឹងឮជាទូទៅក៏ដោយ ក៏សហព្រះរាជអាជ្ញាផ្ទុយទៅវិញមិនបានលើកឡើងអំពីអំណះអំណាងនេះទាល់តែសោះ ដោយគ្រាន់តែបដិសេធចោលដោយមិនមានការពន្យល់ថា "នួន ជា មិនបានបង្ហាញថាវៀតណាម [...] បានដើរតួនាទីក្នុងឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១នោះទេ"[26]។

១០. និយាយតាមបែបផ្សេងទៀតគឺ សហព្រះរាជអាជ្ញាអះអាងមិនត្រឹមត្រូវថា មេធាវីការពារក្តីមិនបានបង្ហាញអំពីរបៀបដែលអំណះអំណាងនិងភស្តុតាងដែលបានបង្ហាញនៅក្នុងសំណើនឹងមានផលប៉ះពាល់ទៅដល់ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ("សាលក្រម")[27]។ សហព្រះរាជអាជ្ញាហាក់ដូចជាមិនបានគិតទៅដល់ការពិតដែលមេធាវីការពារក្តីបានព្យាយាមជាញឹកញាប់ និងដោយប្រុងប្រយ័ត្នធ្វើដូច្នេះនៅទូទាំងសំណើលើកទី៦។ ជាពិសេសខ្លួនបានជ្រើសយកចេញអំពីសារណាកាលពីលើកមុនមកសំអាងជាថ្មីម្តងទៀតអំពីការរកឃើញដែលពាក់ព័ន្ធនៅក្នុងសាលក្រម[28]។ សហព្រះរាជអាជ្ញាបានប្រើប្រាស់ការពន្យល់ចំនួន២៥ទំព័រទៅលើរបៀបដែលភស្តុតាងពាក់ព័ន្ធមានទំនាក់ទំនងអំពីការរកឃើញនោះ[29]។ និងខ្លួនបានបង្ហាញអំណះអំណាងជាក់លាក់អំពីសារសំខាន់នៃភស្តុតាងក្នុងការរារាំងអំពីតម្លៃនៃភស្តុតាងសម្រាប់ការព្យាយាមដ៏សមហេតុផលដែលនាំទៅដល់ការ

---

[25] *សូមមើល* **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៦១៣។ **F2/4/3/3/6/1** "សារណារបស់ នួន ជា អំពីប្រតិចារិតរបស់ Lemkin និងសារសំខាន់នៃ "ជម្លោះ" នៅក្នុង បកក" កថាខណ្ឌ ៦៥។

[26] **F2/8/5**, "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី ៦" កថាខណ្ឌ ៥។

[27] **F2/8/5**, "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី ៦ របស់ នួន ជា សុំឲ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥

[28] **F2/8** "សំណើលើកទី៦" កថាខណ្ឌ ២ ដល់ ៨ និង ១៥១។

[29] **F2/8** "សំណើលើកទី៦" កថាខណ្ឌ ២៣ ដល់ ៦៩។

សម្រេចផ្សេងពីនេះ[30]។ មេធាវីការពារក្តីពិបាកយល់អំពីការដែលសហព្រះរាជអាជ្ញាអាចខកខានក្នុងការពិចារណាអំពីអំណះអំណាងបែបនេះទាល់តែសោះ ជាពិសេសដោយពិចារណាថារយៈពេលប៉ុន្មានថ្ងៃនៅមុនពេលដែលសហព្រះរាជអាជ្ញាដាក់ជូននូវចម្លើយតបនេះ មេធាវីការពារក្តីតាមរយៈសំណើអង្គជំនុំជម្រះ បានដាក់សារណាជូនអង្គជំនុំជម្រះតុលាការកំពូល ដោយស្នើសុំការបញ្ជាក់បន្ថែមអំពីសារសំខាន់នៃអំណះអំណាងរបស់ខ្លួនដែលថា "ជម្លោះ"នៅក្នុង បកក ដែលខ្លួនបានយោងយ៉ាងច្រើនដល់អំណះអំណាងនៅក្នុងសំណើលើកទី៦នោះ[31]។

១១. នៅក្នុងសំណើលើកទី៦ មេធាវីការពារក្តីបានព្យាយាមទាញចំណាប់អារម្មណ៍ទៅដល់ភាពទូទៅនៃ "ការយល់ឃើញទូទៅទាំងស្រុង" Manichean[32] និងបញ្ជាក់អំពីចេតនាល្អ និងតួនាទីនៅក្នុងដំណើការសវនាការ[33] ក្នុងការព្យាយាមធ្វើឲ្យមានការពិភាក្សាក្នុងកម្រិតសំខាន់ថែមទៀត និងទៅឲ្យកាន់តែកៀកក្នុងការស្វែងរកការពិត។ ទោះបីជាយ៉ាងណាក៏ដោយសហព្រះរាជអាជ្ញាបានជ្រើសរើសនៅក្នុងចម្លើយតបដោយមិនគ្រាន់តែនិយាយច្រើនតែអំពីឧទារណ៍របស់ខ្លួនអំពីរឿងនិទានបិសាចនិងព្រះ ក្នុងការច្រានចោលទាំងអស់ប៉ុណ្ណោះទេ តែថែមទាំងប្រើប្រាស់ឱកាសក្នុងការចោទប្រកាន់ទៅដល់ការប្រព្រឹត្តរបស់មេធាវីការពារក្តីទៀតផង[34]។ ការចោទប្រកាន់ធ្ងន់ធ្ងរបែបនេះមិនគួរត្រូវបានលើកឡើងនោះទេ និងចម្លើយតបមិនបានផ្តល់នូវការស្នើមិនសំខាន់ដែលថា ចេតនា ការប្រព្រឹត្ត និង យុទ្ធសាស្រ្តការពារក្តីរបស់មេធាវីការពារក្តីគឺអាក្រក់។ អង្គជំនុំជម្រះមិនគួរគ្រាន់តែបដិសេធនូវចម្លើយតបប៉ុណ្ណោះទេ តែថែមទាំងគួរពិចារណាដល់ការប្រព្រឹត្តខុសបែបនេះរបស់សហព្រះរាជអាជ្ញាដែរ។

## ខ. សហព្រះរាជអាជ្ញាអនុវត្តមិនត្រឹមត្រូវបទដ្ឋានក្នុងការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខ

---

[30] **F2/8** "សំណើលើកទី៦" កថាខណ្ឌ ១៥២ ដល់ ១៥៥។

[31] **F2/4/3/3/6/1** "សារណារបស់ នួន ជា អំពីប្រតិចារិតរបស់ Lemkin និងសារសំខាន់នៃ "ជម្លោះ" នៅក្នុង បកក" កថាខណ្ឌ ១៦ ដល់ ៦៦។

[32] **F2/8** "សំណើលើកទី៦" កថាខណ្ឌ ២១ ដល់ ២២។

[33] **F2/8** "សំណើលើកទី៦" កថាខណ្ឌ ១៧ ដល់ ១៨។

[34] សូមមើលការពិភាក្សានៅ **F2/8** "សំណើលើកទី៦" កថាខណ្ឌ ១៦។

១២. សហព្រះរាជអាជ្ញាអះអាងថា គ្មានឯកសារណាមួយនៅក្នុងសំណើលើកទី៦ "បំពេញបទដ្ឋានសម្រាប់ការទទួលយកឯកសារថ្មីសម្រាប់បណ្ដឹងសាទុក្ខ ដោយសារតែមិនមែន "កត្តាកំណត់មួយ"ដើម្បីចេញសាលក្រមនោះទេ។ ម្យ៉ាងទៀត វាគ្មានផលប្រយោជន៍យុត្តិធម៌ក្នុងការទទួលឯកសារទាំងនេះក្នុងតំណាក់កាលនេះទេ"[35]។ សហព្រះរាជអាជ្ញាលើកឡើងថា វិធាន ១០៤(១) អនុញ្ញាតឲ្យអង្គជំនុំជម្រះតុលាការកំពូលនូវអំណាចឆន្ទានុសិទ្ធិទទួលយកភស្តុតាងថ្មីដើម្បីផលប្រយោជន៍យុត្តិធម៌ នេះ "នឹងដាក់បញ្ចូលជាចាំបាច់នូវការពិចារណាលើកត្តាបីដែលអង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញដោយពាក់ព័ន្ធសម្រាប់ពិចារណាលើភស្តុតាងថ្មីដោយអនុលោមតាមវិធាន ១០៨(៧)"[36]។

១៣. ដូចដែលមេធាវីការពារក្ដីបានឆ្លើយតបកន្លងមកទៅសហព្រះរាជអាជ្ញា[37] តែទោះជាយ៉ាងណាក៏ដោយដូចដែលបានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខថា អង្គជំនុំជម្រះនេះមានអំណាចទូលំទូលាយក្នុងការទទួលយកភស្តុតាងថ្មី។ វិធាន ១០៤(១) អនុញ្ញាតឲ្យអង្គជំនុំជម្រះតុលាការកំពូល "ត្រួតពិនិត្យភស្តុតាង និង ស្វែងរកភស្តុតាងថ្មី" ដើម្បីសម្រេចលើបណ្ដឹងសាទុក្ខ។ អំណាចដ៏ទូលាយនេះគឺស្របទៅនឹងនីតិវិធីនៅក្នុងតុលាការកម្ពុជា និងនៅក្នុងច្បាប់ស៊ីវិលជាទូទៅ ដែលពិចារណាទៅដល់ការវាយតម្លៃ *de novo* នៃភស្តុតាងលើបណ្ដឹងសាទុក្ខ[38]។ ដោយមិនគិតដល់ការតវ៉ាដដែល ដែលគួចចិត្ត និងការនាំផ្លូវខុស ដែលថា អង្គជំនុំជម្រះនេះមានកាតព្វកិច្ចការពារបណ្ដឹងសាទុក្ខពីការធ្វើឲ្យខូចខាតដល់សវនាការលើកទីពីរ ការពន្យាពេលដំណើរការនីតិវិធី និងឬក៏ជំរុញឲ្យរឿងក្ដីមិនគ្រប់លក្ខណៈ"[39]។

---

[35] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៤៥។

[36] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ១៤។

[37] **F2/4/3/3/4** "ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា" កថាខណ្ឌ ៣។

[38] **F16** បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៤ (បណ្ដឹងសាទុក្ខ) កថាខណ្ឌ ២ ដល់ ១៤។

[39] **F2/4/3/3/3** សំណើរ កថាខណ្ឌ ៣; **F2/7/1** "ចម្លើយតបរបស់សហព្រះរាជអជ្ញា ទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឲពិចារណា និងទទួយយកភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខ ប្រឆាំងសាលក្រមរបស់អង្គជំនុំជំរះសាលាដំបូង ក្នុងសំណុំរឿង" ០០២/០១ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥; **F2/6/2** "ចម្លើយតបរបស់សហព្រះរាជអជ្ញា ទៅនឹងសំណើ

១៤. មេធាវីការពារក្តីបានពិភាក្សាគ្នារួចហើយនៅក្នុងការឆ្លើយតបកន្លងមកថា[40] សហព្រះរាជអាជ្ញា បានព្យាយាមប៉ុនប៉ងដោយបរាជ័យជាដដែលក្នុងការលួងលោមអង្គជំនុំជម្រះថា ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការទទួលយកភស្តុតាងថ្មីអំពីបណ្តឹងសាទុក្ខគឺតម្រូវនៅក្នុងវិធាន ១០៨(៧)[41] ។ ផ្ទុយពីអ្វីដែលលើកឡើងដោយសហព្រះរាជអាជ្ញាថា ការពិនិត្យរបស់អង្គជំនុំជម្រះនេះ អំពីប្រយោជន៍យុត្តិធម៌តាមវិធាន ១០៤(១) "ការដាក់បញ្ចូលជាចាំបាច់" រាប់បញ្ចូលទាក់ទងនឹងតេសនៅក្នុងវិធាន ១០៨(៧)[42] អង្គជំនុំជម្រះនេះបានសម្រេចដដែលៗថា វិធានទាំងពីរនេះគឺដាច់ពីគ្នា[43] ហើយថា ខ្លួន "រក្សានូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការទទួលយកភស្តុតាងថ្មីលើបណ្តឹងសាទុក្ខ បើទោះជាការរកឃើញផ្ទុយមួយ ឬច្រើន លើប្រភេទវិធានទទួលយកភស្តុតាងសម្រាប់បណ្តឹងសាទុក្ខ"[44]ក៏ដោយ។ ការតម្រូវនៃវិធាន១០៤(១) និង ១០៨(៧) ទោះជាតាមវិធីណាក៏ដោយ ក៏បានបំពេញដែរ។ ផ្ទុយនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា[45] សំណើលើកទី៦ពិតជាបានលើកឡើងអំពីអំណះអំណាងជាច្រើនបង្ហាញអំពីសារសំខាន់នៃភស្តុតាង

---

ទីបួនរបស់ នួន ជា ស្នើសុំឲ្យពិចារណា និងទទួលយកកភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ ៥។

[40] **F28/3** "ការឆ្លើយតបទៅនឹងព្រះរាជអាជ្ញាអំពី សំ សិទ្ធី" កថាខណ្ឌ ២៧។

[41] ឯកសារ **F2/3/3/3**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានា ស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងឈុតវីដេអូដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Rob Lemkin និង ថេតសម្បត្តិ, ថ្ងៃទី ២៣ កក្កដា ឆ្នាំ ២០១៥, កថាខណ្ឌ ៧។ ឯកសារ **F2/7/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ១៣ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ៤។

[42] ឯកសារ **F28**, សំណើ កថាខណ្ឌ ៩។

[43] ឯកសារ **F2/5** "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ" ថ្ងៃទី ២៩ ឧសភា ឆ្នាំ២០១៥ កថាខណ្ឌ ១៥ ដល់ ១៧ (លក្ខណៈវិធាន ១០៤(១) និង ១០៨(៧) តាម "វិធីពីរ" សម្រាប់ការទទួលយកភស្តុតាងសម្រាប់បណ្តឹងឧទ្ធរណ៍)។

[44] ឯកសារ **F2/5** "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ" ថ្ងៃទី ២៩ ឧសភា ឆ្នាំ២០១៥ ជើងទំព័រ ៥១ (ដកស្រង់ សាលក្រម *Lubanga* កថាខណ្ឌ ៦២)

[45] **F2/8/5** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦" កថាខណ្ឌ ៤៥ សូមមើលផងដែរ កថាខណ្ឌ ៧ ខាងលើ។

ដែលបានស្នើសុំឲ្យទទួលយកសម្រាប់សាលក្រម និងសេចក្តីសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា។

១៥. ដំណើរការនីតិវិធីនៅចំពោះមុខ អវតក ត្រូវបានចំណាយពេលវេលាយ៉ាងច្រើន។ អវតក ទំនងជាវេទិការច្បាប់ក្នុងការស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ អាស្រ័យហេតុនេះហើយ វាជាក្តីរំពឹងរបស់មេធាវីការពារក្តីថា សហព្រះរាជអាជ្ញា នឹងអាចឆ្លងផុតពី វិធានការ"ផ្សែង និង កញ្ចក់" ដោយគ្រាន់តែស្តីបន្ទោសមេធាវីការពារក្តី ហើយផ្ទុយទៅវិញងាកមកពិភាក្សាជាមួយមេធាវីការពារក្តីអំពីអ្វី ដែលអាចជាការពិតដែលសាធារណជនកម្ពុជា និង សហគមន៍អន្តរជាតិត្រូវការ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE